ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង.ធ.ន.ស.
លេខ 3077
ថ្ងៃខែ 4.7.22
ហត្ថលេខា

ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួង.ធ.ន.ស.
ចូល ថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ២០២២
ម៉ោង ១៦:២៣

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ : ៥០៦ ស.ស.ណ.ឯ.ម

ថ្ងៃ ព្រហស្បតិ៍ ២ កើត ខែ អាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ជម្រាបជូន**

**-ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**-ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**-ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម**
**-ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង**

**កម្មវត្ថុ៖** ករណីសំណើសុំកែសម្រួលផ្ទៃដីចំនួន ៥ទីតាំង ទំហំ ៩៨៧ហិកតា ៩៥អា ចេញពីតំបន់២ នៃតំបន់ទន្លេសាប បញ្ចូលមកតំបន់១ ក្នុងភូមិសាស្ត្រស្រុកមោងឫស្សី ខេត្តបាត់ដំបង និងផ្តល់សិទ្ធិជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១ ២០៩គ្រួសារ ដែលបានរស់នៅអចិន្ត្រៃយ៍ និងអាស្រ័យផលយូរឆ្នាំមកហើយ។

**យោង ៖**
- លិខិតលេខ១៦៨៩ ដនស/អសដក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- លិខិតលេខ៣០៨ ខន/០២២ សជណ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២ របស់ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមជ្រាបថា រាជរដ្ឋាភិបាលសម្រេចកែសម្រួលផ្ទៃដីចំនួន ៥ទីតាំង ទំហំ ៩៨៧ហិកតា ៩៥អា ស្ថិតនៅភូមិសាស្ត្រស្រុកមោងឫស្សី ខេត្តបាត់ដំបង ចេញពីតំបន់២ បញ្ចូលមកតំបន់១ ដូចមានផែនទីនិងតារាងនិយាមកាភ្ជាប់មកជាមួយ និងផ្តល់សិទ្ធិជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១ ២០៩គ្រួសារ ដែលរស់នៅអចិន្ត្រៃយ៍ និងអាស្រ័យផលយូរឆ្នាំមកហើយ ដូចខាងក្រោម៖

-ទីតាំងទី១ ស្ថិតនៅភូមិថ្មី ឃុំព្រៃតូច ទំហំ ១២៨ហិកតា ៨៥អា ជូនប្រជាពលរដ្ឋចំនួន ៧២គ្រួសារ

-ទីតាំងទី២ ស្ថិតនៅភូមិទួលព្រំ២ ឃុំកកោះ ទំហំ ១១៤ហិកតា ១៧អា ជូនប្រជាពលរដ្ឋចំនួន ១០៥គ្រួសារ

-ទីតាំងទី៣ ស្ថិតនៅភូមិម៉ាណោក ឃុំតាលាស់ ទំហំ ១៣៧ហិកតា ៧៣អា ជូនប្រជាពលរដ្ឋចំនួន ១៥១គ្រួសារ

-ទីតាំងទី៤ ស្ថិតនៅភូមិដូនទ្រី ឃុំជ្រៃ ទំហំ ៥៧១ហិកតា ៥១អា ជូនប្រជាពលរដ្ឋចំនួន ៥៣៥ គ្រួសារ

-ទីតាំងទី៥ ស្ថិតនៅភូមិអ្នកតាទ្វា ឃុំឫស្សីក្រាំង ទំហំ ៣៥ហិកតា ៦៩អា ជូនប្រជាពលរដ្ឋចំនួន ៣៤៦គ្រួសារ។

អាស្រ័យដូចបានជម្រាបជូនខាងលើសូមឯកឧត្តមជ្រាបនិងបាត់ចែងអនុវត្ត។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**ឈួន សុធី**

**ចម្លងជូនៈ**
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងបរិស្ថាន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមកិត្តិនីតិកោសលបណ្ឌិតឧបនាយករដ្ឋមន្ត្រីប្រចាំការ
- អាជ្ញាធរទន្លេសាប
- រដ្ឋបាលជលផល
- ឯកសារ កាលប្បវត្តិ